**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានយោធសេវា**
**នាយកដ្ឋានព័ត៌មាន**
លេខ:.......................

# សេចក្តីប្រកាសជូនព័ត៌មាន

តបតាមការអញ្ជើញរបស់ **ឯកឧត្តម ឧត្តមសេនីយ៍ឯក ចាន់ សាម៉ន ចាន់ញ៉ាឡាត** រដ្ឋមន្ត្រី ក្រសួងការពារប្រទេសនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ **សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នឹងដឹកនាំគណៈប្រតិភូជាន់ខ្ពស់ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញធ្វើទស្សនកិច្ចការងារជាផ្លូវការ និងមិត្តភាព នៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចាប់ពីថ្ងៃទី១៣ ដល់១៧ ខែមករា ឆ្នាំ២០១៨។

ក្នុងអំឡុងពេលបំពេញទស្សនកិច្ចផ្លូវការនេះ **សម្តេចពិជ័យសេនា ទៀ បាញ់** ព្រមទាំងប្រតិភូ នឹងជួបប្រជុំទ្វេភាគីជាមួយ **ឯកឧត្តម ឧត្តមសេនីយ៍ឯក ចាន់សាម៉ន ចាន់ញ៉ាឡាត** រដ្ឋមន្ត្រីក្រសួងការពារប្រទេសឡាវ ព្រមទាំងជួបសំណេះសំណាលការងារជាមួយរដ្ឋមន្ត្រីការពារប្រទេសទាំង៣ **កម្ពុជា-វៀតណាម-ឡាវ** នៅទីក្រុងវៀងច័ន្ទផងដែរ។

ក្នុងឱកាសបំពេញទស្សនកិច្ចជាផ្លូវការ និងមិត្តភាពនៅប្រទេសឡាវ **សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នឹងជួបប្រជុំទ្វេភាគីជាមួយ **ឯកឧត្តម នាយឧត្តមសេនីយ៍ ង៉ូ ស៊ុនលិច្យ** រដ្ឋមន្ត្រីក្រសួងការពារប្រទេស នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ព្រមទាំងចុះហត្ថលេខាលើពិធីសារ ស្តីពីកិច្ចសហប្រតិបត្តិការរវាងក្រសួងការពារប្រទេសទាំង២ កម្ពុជា-វៀតណាមប្រចាំឆ្នាំ២០១៨។

ថ្ងៃ ពុធ ៩រោច ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១០ ខែ មករា គ.ស ២០១៨